**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

លេខៈ ០២៧ សជណ/កសស/រប.ធម

ថ្ងៃ ព្រហស្បតិ៍ ០៩ កើត ខែ ជេស្ឋ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ខេត្តព្រះសីហនុ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០២១

# សេចក្តីជូនដំណឹង

## ស្តីពី

## ការជ្រើសរើសបេក្ខជនឈរឈ្មោះជាអភិបាលឯករាជ្យ សម្រាប់ជាសមាជិកក្រុមប្រឹក្សាភិបាល កំពង់ផែស្វយ័តក្រុងព្រះសីហនុ អាណត្តិទី៨

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស)** ជាសហគ្រាសសាធារណៈ បោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅលើផ្សារមូលបត្រកម្ពុជា នាថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៧ ។ **កសស** ជាកំពង់ផែអន្តរជាតិសមុទ្រទឹកជ្រៅ ដែលដើរតួនាទីជាប្រតិបត្តិករផែ និងអាជ្ញាធរផែ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

យោងតាមលក្ខន្តិកៈរបស់ **កសស** ក្រុមប្រឹក្សាភិបាលអាណត្តិទី៨ ត្រូវមានសមាសភាពចំនួន ០៧ (ប្រាំពីរ) រូប ដែលក្នុងនោះ ០១ (មួយ) រូប ជាអភិបាលឯករាជ្យ ។

អាស្រ័យហេតុនេះ **កសស** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ឲ្យបានជ្រាបថា ៖ **កសស** នឹងចាប់ផ្តើមទទួលពាក្យរបស់បេក្ខជនដែលមានបំណងឈរឈ្មោះជាអភិបាលឯករាជ្យ សម្រាប់ដាក់ជូនមហាសន្និបាតភាគហ៊ុនិកលើកទី៤ ធ្វើការបោះឆ្នោតជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាភិបាល សម្រាប់អាណត្តិទី៨ ដែលមានរយៈពេល ០៣ (បី) ឆ្នាំ ។

### ១. លក្ខខណ្ឌ និងគុណវុឌ្ឍិ នៃការជ្រើសរើស

បេក្ខជនដែលមានបំណងដាក់ពាក្យឈរឈ្មោះជាអភិបាលអភិបាលឯករាជ្យ ត្រូវបំពេញលក្ខខណ្ឌ និងមានគុណវុឌ្ឍិ ដូចខាងក្រោម៖

#### ១.១ លក្ខខណ្ឌនៃការជ្រើសរើស

- ត្រូវមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្រសមមូល ខាងផ្នែកគណនេយ្យ/ហិរញ្ញវត្ថុ
- ត្រូវមានអាយុចាប់ពី ៣៥ (សាមសិបប្រាំ) ឆ្នាំ ឡើងទៅ (គិតត្រឹមថ្ងៃដាក់ពាក្យ)
- ត្រូវមានបទពិសោធន៍ការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ និងឯកទេស ខាងផ្នែកគណនេយ្យ/ហិរញ្ញវត្ថុ
- ចំពោះបេក្ខជន ដែលជាជនបរទេស ត្រូវមានបទពិសោធន៍ការងារក្នុងប្រទេសកម្ពុជាយ៉ាងតិច រយៈពេល ០៦ (ប្រាំមួយ) ខែ
- មិនធ្លាប់ត្រូវបានផ្តន្ទាទោសជាបទវិន័យរដ្ឋបាល ដែលបញ្ជាក់ដោយអង្គភាពដែលខ្លួនបម្រើការងារ (ត្រូវប្រគល់លិខិតបញ្ជាក់ក្រោយពីត្រូវបានបោះឆ្នោតជ្រើសតាំង)



តិវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat N° 3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax : 034 933 693
E-mail : pasinfo@pas.gov.kh; spsez@pas.gov.kh
Website: www.pas.gov.kh

- មិនត្រូវមានធនក្ស័យផ្ទាល់ខ្លួន ដែលបានប្រកាសដោយតុលាការ (ត្រូវប្រគល់លិខិតបញ្ជាក់ក្រោយពីត្រូវបានបោះឆ្នោតជ្រើសរើសតាំង)
- ត្រូវមានលិខិតថ្កោលទោស ដែលបញ្ជាក់ថាមិនធ្លាប់បានផ្តន្ទាទោសក្នុងបទមជ្ឈិម ឬបទឧក្រិដ្ឋ (ត្រូវប្រគល់លិខិតបញ្ជាក់ក្រោយពីត្រូវបានបោះឆ្នោតជ្រើសតាំង) ។

### ១.២ គុណវុឌ្ឍិរបស់បេក្ខជន

- មិនត្រូវបានជួលដោយ **កសស** ក្នុងរយៈពេល ០១ (មួយ) ឆ្នាំចុងក្រោយ
- មិនមានទំនាក់ទំនងជាមួយអតិថិជន ឬអ្នកផ្គត់ផ្គង់ដ៏សំខាន់របស់ **កសស**
- មិនមានកិច្ចសន្យាផ្ទាល់ខ្លួនជាមួយ កសស ឬជាមួយបុគ្គលិកជាន់ខ្ពស់របស់ **កសស**
- មិនជាប់ទាក់ទងជាមួយអង្គការ ឬសមាគមមិនស្វែងរកប្រាក់ចំណេញណាមួយដែលធ្លាប់ទទួលមូលនិធិពី **កសស**
- មិនមែនជាសមាជិកក្រុមគ្រួសាររបស់បុគ្គលដែលធ្លាប់ធ្វើជាអភិបាលឲ្យ **កសស** ឬធ្លាប់បានជួលដោយ **កសស** ឲ្យធ្វើជាអគ្គនាយក ឬបុគ្គលិកជាន់ខ្ពស់ក្នុងរយៈពេល ០១ (មួយ) ឆ្នាំចុងក្រោយ
- មិនធ្លាប់ធ្វើជាសវនករ ក្នុងរយៈពេល ០១ (មួយ) ឆ្នាំចុងក្រោយ ឬកំពុងធ្វើជាសវនករឲ្យ **កសស**
- មិនមែនជានិយោជិតរបស់ **កសស** ឬជាមន្ត្រីរាជការ ។

## ២. សំណុំលិខិតក្នុងការដាក់ពាក្យឈរឈ្មោះ

- ជីវប្រវត្តិរូបសង្ខេប (CV) មានបិទរូបថត (៤x៦) ចំនួន ០១ ច្បាប់
- លិខិតបង្ហាញចំណាប់អារម្មណ៍ (Cover Letter) ចំនួន ០១ ច្បាប់
- សេចក្តីចម្លងសញ្ញាបត្រដែលមានការបញ្ជាក់ត្រឹមត្រូវ ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ការងារ (Recommendation Letter) ចំនួន ០១ ច្បាប់

## ៣. ភារកិច្ចទទួលខុសត្រូវ

- ជាប្រធានគណៈកម្មាធិការសវនកម្ម
- ពិនិត្យរបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ
- ពិនិត្យការត្រួតពិនិត្យផ្ទៃក្នុង
- ពិនិត្យការធ្វើសវនកម្មផ្ទៃក្នុង និងខាងក្រៅ
- រាយការណ៍ជូនក្រុមប្រឹក្សាភិបាលពីសកម្មភាពរបស់ខ្លួន ។

## ៤. អត្ថប្រយោជន៍ដែលទទួលបាន

- ប្រាក់បៀវត្សប្រចាំខែ
- ការឧបត្ថម្ភជូននូវមធ្យោបាយធ្វើដំណើរ និងប្រេងឥន្ធនៈប្រចាំខែ
- ប្រាក់ឧបត្ថម្ភថ្លៃអាហារប្រចាំខែ
- ប្រាក់ថ្លែងសរសើរប្រចាំឆ្នាំ
- ឧបត្ថម្ភសំលៀកបំពាក់ប្រចាំឆ្នាំ
- ប្រាក់ឧបត្ថម្ភផ្សេងៗទៀត នាឱកាសបុណ្យចូលឆ្នាំសកល ចូលឆ្នាំប្រពៃណីជាតិខ្មែរ បុណ្យភ្ជុំបិណ្ឌ និងពិធីបុណ្យជាតិផ្សេងៗទៀត ។



តិរវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat N°3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax : 034 933 693
E-mail : pasinfo@pas.gov.kh; spsez@pas.gov.kh
Website: www.pas.gov.kh

**៥. ទីកន្លែងកាលបរិច្ឆេទនៃការទទួលពាក្យ និងឈប់ទទួលពាក្យ**

- **កាលបរិច្ឆេទចាប់ផ្តើមទទួលពាក្យ**
  ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០២១ រៀងរាល់ម៉ោងធ្វើការងារ
- **កាលបរិច្ឆេទឈប់ទទួលពាក្យ**
  ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២១ វេលាម៉ោង ១៦:០០ ជាកំហិត ។
- **ទីកន្លែងទទួលពាក្យ និងទំនាក់ទំនងព័ត៌មាន**
  នាយកដ្ឋាន រដ្ឋបាល-ធនធានមនុស្ស នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ
  ជាន់ទី ១ នៃអគាររដ្ឋបាល កំពង់ផែស្វយ័តក្រុងព្រះសីហនុ
  តិរវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, សង្កាត់លេខ ៣, ក្រុង- ខេត្តព្រះសីហនុ
  ទូរស័ព្ទ : ០៣៤ ៩៣៣ ៤១៦ , ០៣៤ ៩៣៣ ៥១១ , ០៣៤ ៩៣៣ ៧៣៩
  ទូរសារ : ០៣៤ ៩៣៣ ៦៩៣ , ០៣៤ ៩៣៣ ៧៣៩ , ០៣៤ ៩៣៣ ៩៣១
  សារអេឡិចត្រូនិក : pasinfo@pas.gov.kh
  គេហទំព័រ : www.pas.gov.kh ។

  **ឬតាមរយៈលេខទូរស័ព្ទ និងតេឡេក្រាម** ( Telegram )
  ទូរស័ព្ទ: (៨៥៥) ១០ ៧៨៨ ៨៨០ / ៩៥ ៦៦៨ ៨៩៧ / ១១ ៨១៧ ៨៤៧ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជាប្រធានអគ្គនាយក**

PORT AUTONOME DE SIHANOUKVILLE

**លូ_គឹមឈន់**

**ចម្លងជូនៈ**
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- និយ័តករមូលបត្រកម្ពុជា
- ក្រុមប្រឹក្សាភិបាល កសស
  **"ដើម្បីជូនជ្រាប"**
- ផ្សារមូលបត្រកម្ពុជា និង ក្រុមហ៊ុនមូលបត្រ
  **"ដើម្បីជូនផ្សព្វផ្សាយ"**
- ឯកសារ-កាលប្បវត្តិ



តិរវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat N°3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax : 034 933 693
E-mail : pasinfo@pas.gov.kh; spsez@pas.gov.kh
Website: www.pas.gov.kh